**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើត បញ្ជាការដ្ឋានអង្គរក្ស

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០( ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោ ពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀប និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួ រចនាសម្ព័ន្ធ និងប្តូរឈ្មោះ ខុទ្ទកាល័យក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋា ក្រសួងការពារជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបង្កើត បញ្ជាការដ្ឋាន អង្គរក្ស ដាក់ចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** បញ្ជាការដ្ឋាន អង្គរក្ស ស្ថិតក្រោមការដឹកនាំ បញ្ជាផ្ទាល់ របស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងការពារជាតិ និង អគ្គបញ្ជាការដ្ឋាន ជាអ្នកធានា ផ្គត់ផ្គង់សម្ភារ ហិរញ្ញវត្ថុ គ្រឿងបំពាក់ កំលាំង និងហ៊ីកហ៊ឺន ។

**មាត្រា៣** : រចនាសម្ព័ន្ធចាត់តាំង បញ្ជាការដ្ឋាន អង្គរក្ស រួមមាន :

- មេបញ្ជាការ
- មេបញ្ជាការរង
- នាយសេនាធិការ
- នាយសេនាធិការរង
- ខុទ្ទកាល័យ
- ស្នងការដ្ឋាន បុគ្គលិក-បណ្តុះបណ្តាល
- ស្នងការដ្ឋាន ស្រាវជ្រាវ-សន្តិសុខ
- ស្នងការដ្ឋាន ប្រតិបត្តិការ
- ស្នងការដ្ឋាន ឃោសនា-ព័ត៌មាន
- ស្នងការដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ
- ស្នងការដ្ឋាន សំភារៈ-បច្ចេកទេស
- ស្នងការដ្ឋាន សង្គមកិច្ច-អភិវឌ្ឍន៍
- មជ្ឈមណ្ឌលហ្វឹកហ្វឺន

ព្រមទាំងបណ្តាការិយាល័យ និងកងវរសេនាតូចចំណុះមួយចំនួនទៀត ។

**មាត្រា៤** : បញ្ជាការដ្ឋាន អង្គរក្ស មានតួនាទី ភារកិច្ច ដូចខាងក្រោម :

- ការពារសន្តិសុខ សុវត្ថិភាព នាយករដ្ឋមន្ត្រី និង លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ។
- ការពារសន្តិសុខ សុវត្ថិភាពដល់ស្ថាប័ន និងឥស្សរជនជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា តាមបទបញ្ជារបស់ នាយករដ្ឋមន្ត្រី ។
- ចូលរួមការពារសន្តិសុខ សុវត្ថិភាព ជូនថ្នាក់ដឹកនាំជាន់ខ្ពស់អន្តរជាតិ ដែលមានបេសកកម្មនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។
- សហការជាមួយបណ្តាស្ថាប័នកងឯកភាពចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ កងរាជអាវុធហត្ថ អាជ្ញាធរមាន សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ស្ថាប័ន និងកងឯកភាពពាក់ព័ន្ធ ដើម្បីការពារទប់ស្កាត់ និង បង្ក្រាបនូវរាល់អំពើវិទ្ធង្សនា កុប្បកម្ម បាតុកម្ម ដែលប៉ះពាល់ដល់ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ។
- ចូលរួមធ្វើការងារសង្គមកិច្ច សាសនា និងការអភិវឌ្ឍន៍ តាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី ។
- ក្រៅពីភារកិច្ចខាងលើ បញ្ជាការដ្ឋានអង្គរក្ស ត្រូវបានបំពេញភារកិច្ចផ្សេងទៀត តាមការបញ្ជារបស់នាយករដ្ឋមន្ត្រី ។
- បញ្ជាការដ្ឋានអង្គរក្សក្រៅពីប្រើប្រាស់ឯកសណ្ឋានយោធាមានសិទ្ធិប្រើប្រាស់ ឯកសណ្ឋានអង្គរក្ស និងឯកសណ្ឋាន ដទៃទៀត តាមតំរូវការភារកិច្ច ។

**មាត្រា៥** : រចនាសម្ព័ន្ធ និងក្របខ័ណ្ឌចំនួនទ័ពលំអិត របស់បញ្ជាការដ្ឋានអង្គរក្ស អាស្រ័យដោយក្រសួងការពារជាតិកំណត់ ។

**មាត្រា៦ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- ឯកសារ-កាលប្បវត្តិ